អេស៊ីលីដា
ACLEDA BANK

# របាយការណ៍ប្រចាំត្រីមាសទី២

## គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាលានរៀល) | ត្រីមាសទី២ ឆ្នាំ២០២១ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ២៩.៦៣៨.៧៥២ | ២៦.៥០០.៧៩៣ | ២៥.១៦៣.៧៨៤ |
| បំណុលសរុប | ២៤.៨៥៣.២៨៣ | ២២.០៩៣.២៥៨ | ២១.២៣៣.៦០៣ |
| មូលធនសរុប | ៤.៧៨៥.៤៦៩ | ៤.៤០៧.៥៣៥ | ៣.៩៣០.១៨១ |
| **លទ្ធផលហិរញ្ញវត្ថុ (គិតជាលានរៀល)** | **ត្រីមាសទី២ ឆ្នាំ២០២១** | **ត្រីមាសទី២ ឆ្នាំ២០២០** | **ត្រីមាសទី២ ឆ្នាំ២០១៩** |
| ចំណូលសរុប | ៦២៥.៥១៧ | ៥៧១.២៤១ | ៥៦៥.២៧៥ |
| ចំណេញ/(ខាត) មុនបង់ពន្ធ | ១៨៧.៥៨៧ | ១៥៩.២០៣ | ១៤៩.៤៥៤ |
| ចំណេញ/(ខាត) សុទ្ធក្នុងការិយបរិច្ឆេទ | ១៥០.៧៩៦ | ១២៣.៨១៤ | ១២០.៥០៧ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ១៥៥.៩១៧ | ១២២.១៣២ | ១២២.០០៦ |
| **អនុបាតហិរញ្ញវត្ថុ (%)** | **ត្រីមាសទី២ ឆ្នាំ២០២១** | **ឆ្នាំ២០២០** | **ឆ្នាំ២០១៩** |
| អនុបាតសាធនភាព | ២៤,៩៣% | ២៥,១៥% | ២៦,៣១% |
| អនុបាតបំណុលធៀបនឹងមូលធន | ៥១៩,៣៥% | ៥០១,២៦% | ៥៤០,២៧% |
| អនុបាតក្របខ័ណ្ឌសន្ទនីយភាព | ១៧០,៤៩% | ១៤៩,៣១% | ១៦៧,២៧% |
| អនុបាតឥណទានមិនដំណើរការ (*) | ២,៥០% | ២,៤០% | ១,២៤% |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ៩២,០៩% | ៩៧,៧៣% | ៨៨,៨២% |
| | **ត្រីមាសទី២ ឆ្នាំ២០២១** | **ត្រីមាសទី២ ឆ្នាំ២០២០** | **ត្រីមាសទី២ ឆ្នាំ២០១៩** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)(**) | ០,៥២% | ០,៤៩% | ០,៤៩% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE) (**) | ៣,២៣% | ៣,០៧% | ៣,៣៤% |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ដង) | ២,០៩ | ២,០៣ | ១,៩១ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ៣៨៤,៨២ | ២៨៧,៥៥ | ៣០១,៥៣ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | គ្មាន | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | គ្មាន | គ្មាន | គ្មាន |

(*) ឥណទានមិនដំណើរការ = ឥណទាននៅដំណាក់កាលទី៣

(**) . អនុបាតទាំងនេះមិនមែនជាអនុបាតប្រចាំឆ្នាំនោះទេ ហើយត្រូវបានគណនាដោយប្រើតួលេខប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគាររយៈពេល ៣ខែ ចាប់ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។

. ចំណេញធៀបនឹងមូលធនមធ្យម = ប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ / មូលធនសរុបមធ្យមរបស់ភាគហ៊ុនិករបស់ធនាគារ

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប







អនុបាតហិរញ្ញវត្ថុ(%)
៦០០%
៥០០%
៤០០%
៣០០%
២០០%
១០០%
០%
២៤,៩៣%
២៥,១៥%
២៦,៣១%
៥១៩,៣៥%
៥០១,២៦%
៥៤០,២៧%
១៧០,៤៩%
១៤៩,៣១%
១៦៧,២៧%
២,៥០%
២,៤០%
១,២៤%
៩២,០៩%
៩៧,៧៣%
៨៨,៨២%
អនុបាតសាធនភាព
អនុបាតបំណុលធៀបនឹងមូលធន
អនុបាតក្របខ័ណ្ឌសន្ទនីយភាព
អនុបាតឥណទានមិនដំណើរការ
អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ
ត្រីមាសទី២ ឆ្នាំ២០២១
ឆ្នាំ២០២០
ឆ្នាំ២០១៩


៣,២៣%
៣,០៧%
៣,៣៤%
០,៥២%
០,៤៩%
០,៤៩%
អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)
អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE)
ត្រីមាសទី២ ឆ្នាំ២០២១
ត្រីមាសទី២ ឆ្នាំ២០២០
ត្រីមាសទី២ ឆ្នាំ២០១៩


ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ
៣០១,៥៣
២៨៧,៥៥
៣៤៨,៨២
ត្រីមាសទី២ ឆ្នាំ២០១៩
ត្រីមាសទី២ ឆ្នាំ២០២០
ត្រីមាសទី២ ឆ្នាំ២០២១

# សមាសភាពក្រុមប្រឹក្សាភិបាល



លោក ឆាយ សឿន

*ប្រធានក្រុមប្រឹក្សាភិបាល*



បណ្ឌិត អ៊ិន ចាន់នី

*អភិបាលប្រតិបត្តិ*



លោក រ័ត្ន យូម៉េង

*អភិបាលប្រតិបត្តិ*



លោក Stéphane Mangiavacca

*អភិបាលមិនប្រតិបត្តិ*



លោក Kenichiro Mori

*អភិបាលមិនប្រតិបត្តិ*



លោក Albertus Bruggink

*អភិបាលមិនប្រតិបត្តិ*



លោក កាយ ឡូត

*អភិបាលមិនប្រតិបត្តិ*



លោក Pieter Kooi

*អភិបាលឯករាជ្យ*



លោក Ian Samuel Lydall

*អភិបាលឯករាជ្យ*



លោក វ៉ាន់ ស៊ូអៀង

*អភិបាលឯករាជ្យ*

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

តាងនាមឲ្យធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ”) និងក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមផ្តល់ជូននូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី២ ឆ្នាំ២០២១ របស់ធនាគារ គិតចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។

ដោយសារការអូសបន្លាយនៃការឆ្លងចូលសហគមន៍នៃជំងឺកូវីដ-១៩ សម្រាប់ព្រឹត្តិការណ៍ថ្ងៃ២០កុម្ភៈនៅកម្ពុជា រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការតឹងរ៉ឹងមួយចំនួន ដែលរួមមាន ៣កុំ ៣ការពារ ការបិទខ្ទប់រាជធានីភ្នំពេញ និងក្រុងតាខ្មៅ ការរឹតបន្តឹងចរាចរណ៍ ជាបន្តបន្ទាប់ក្នុងតំបន់ខ្លះនៃរាជធានីភ្នំពេញ ការពន្លឿនការចាក់វ៉ាក់សាំងបង្ការជំងឺ និងការធ្វើតេស្តរហ័ស ដើម្បីការពារការឆ្លង និងការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ដូចជាដើម្បីជួយសង្គ្រោះ និងស្តារឡើងវិញនូវសេដ្ឋកិច្ចរបស់កម្ពុជា។

ឈរលើមូលដ្ឋានដ៏រឹងមាំនៃផែនការយុទ្ធសាស្ត្ររបស់ធនាគារ ដើម្បីក្លាយជាធនាគារឌីជីថលឈានមុខក្នុងតំបន់ តាមរយៈការព្យាករ និងការវិភាគយ៉ាងហ្មត់ចត់អំពីតម្រូវការដ៏ច្រើនសន្ធឹកសន្ធាប់លើផលិតផល និងសេវាកម្មធនាគារឌីជីថល មុនពេលមានការឆ្លងជំងឺនេះចូលសហគមន៍ ធនាគារបាននិងកំពុងផ្តោតសំខាន់លើការកើនឡើងយ៉ាងខ្លាំងនៃចំនួនអ្នកចុះឈ្មោះប្រើប្រាស់កម្មវិធី **អេស៊ីលីដាម៉ូបាល** ជាមួយនឹងការជំរុញ និងទំនាក់ទំនងក្នុងភាពជាដៃគូជាច្រើន ដែលមិនត្រឹមតែទាក់ទាញអ្នកដាក់ប្រាក់បញ្ញើប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងបង្កើនការទិញ និងការប្រើប្រាស់នូវផលិតផល និងសេវាកម្មផ្សេងៗ របស់ធនាគារ ក៏ដូចជាការបង្កើនផលិតភាព និងជំនាញការងាររបស់កម្មករនិយោជិត។ ក្រៅពីនេះ ធនាគារនឹងបន្តរៀបចំការិយាល័យឡើងវិញ ដើម្បីប្រែក្លាយទៅជាធនាគារឌីជីថល ដែលមានលក្ខណៈកាន់តែសម្បូរបែបនៅក្នុងតំបន់។ ម៉ាស៊ីនដកប្រាក់ ម៉ាស៊ីនដាក់ប្រាក់ ម៉ាស៊ីនបើកគណនី និងបោះពុម្ពប័ណ្ណអេធីអឹម និងម៉ាស៊ីនបើកគណនីមានកាលកំណត់ និងបោះពុម្ពប័ណ្ណ នឹងត្រូវបំពាក់បន្ថែមជាមួយនឹងម៉ាស៊ីនឆូតកាត និងកម្មវិធី **អេស៊ីលីដាម៉ូបាល** ដែលមានបច្ចេកវិទ្យាចុងក្រោយ និងប្រកបដោយសុវត្ថិភាពនោះ អាចទាក់ទាញ និងជួយឲ្យអតិថិជនធ្វើស្វ័យប្រតិបត្តិការធនាគារតាមអនឡាញបានកាន់តែងាយស្រួល រហ័ស និងរលូនពីគ្រប់ទីកន្លែង និងនៅគ្រប់ពេលវេលា។

ក្នុងអំឡុងពេលនៃការឆ្លងជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ ធនាគារនៅតែបន្តអនុវត្តនូវវិធានការបង្ការការឆ្លងនេះដដែល ដើម្បីធានាសុខភាព និងសុខុមាលភាពជូនដល់កម្មករនិយោជិតរបស់ខ្លួន និងបានអនុវត្តការងារពីចម្ងាយ ដោយកម្មករនិយោជិតយ៉ាងហោច ៥០% នៃកម្មករនិយោជិតទាំងអស់នៅក្នុងនាយកដ្ឋាន និងការិយាល័យ តាមរយៈការផ្លាស់ប្តូរវេនគ្នាក្នុងមួយសប្តាហ៍ម្តង ដើម្បីរក្សាប្រតិបត្តិការរបស់ធនាគារឲ្យដំណើរការដោយរលូន និងប្រកបដោយសុវត្ថិភាព។ ក្នុងត្រីមាសនេះ ធនាគារសម្រេចបាននូវលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ប្រាក់បញ្ញើសរុបបានកើនឡើងចំនួន ៦១៤,៩៤ លានដុល្លារអាមេរិក ហើយសមតុល្យឥណទានសរុបបានកើនឡើងចំនួន ៣០៦,០៧ លានដុល្លារអាមេរិក បើធៀបនឹងដំណាច់ឆ្នាំ២០២០។ ប្រសិនបើធៀបនឹងដំណាច់ខែមិថុនា ឆ្នាំ ២០២០ ប្រាក់បញ្ញើសរុប និងសមតុល្យឥណទានសរុបបានកើនឡើងចំនួន ៨៥០,៥០ លានដុល្លារអាមេរិក (១៩,៤៤%) និង ៨៩៩,៥៩ លានដុល្លារអាមេរិក (២២,៩៩%) តាមលំដាប់។

ធនាគារទទួលបានប្រាក់ចំណេញសុទ្ធចំនួន ៣៧,១៧ លានដុល្លារអាមេរិក ដោយកើនឡើង ២៣,២៤% ស្មើនឹង ៧,០១ លានដុល្លារអាមេរិក បើធៀបនឹងត្រីមាសទី២ដូចគ្នា ក្នុងឆ្នាំ២០២០។ សម្រាប់ត្រីមាសទី២ ឆ្នាំ២០២១ នេះ ធនាគារទទួលបានអនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យមចំនួន ០,៥២% និងទទួលបានអនុបាតចំណេញធៀបនឹងមូលធនមធ្យមចំនួន ៣,២៣%។

ជាទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណ និងសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះភាគីពាក់ព័ន្ធ អតិថិជន និងជាពិសេសអាជ្ញាធរពាក់ព័ន្ធទាំងអស់ ដែលបានបន្តការជ្រោមជ្រែង និងការគាំទ្រដល់ធនាគារ។

ថ្ងៃអង្គារ ២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១
ហត្ថលេខា និងត្រា

ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA BANK PLC.

**ឆាយ សឿន**

# មាតិកា

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ ii

សមាសភាពក្រុមប្រឹក្សាភិបាល ........ iv

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ........ v

**ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១**

**ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១**

**ខ- លក្ខណៈនៃធុរកិច្ច ........ ១**

**គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១**

**ផ្នែកទី ២-ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ ២**

**ក-លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ........ ២**

**ខ-រចនាសម្ព័ន្ធចំណូល ........ ៤**

**ផ្នែកទី ៣-របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ ........ ៥**

**ផ្នែកទី ៤-ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ........ ៦**

**ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ ៦**

**ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ........ ៩**

**គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ........ ១០**

**ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ........ ១០**

**ង-ផលប៉ះពាល់នៃអតិផរណា ........ ១១**

**ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ........ ១១**

**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១៣**

## ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

### ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ អេស៊ីលីដា ភីអិលស៊ី** |
| ជាអក្សរឡាតាំង | **ACLEDA Bank Plc.** |
| លេខកូដស្តង់ដារ | KH១០០០១០០០០៣ |
| ទីស្នាក់ការ | អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (០)២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ |
| លេខទូរសារ | +៨៥៥ (០)២៣ ៤៣០ ៥៥៥ |
| គេហទំព័រ | www.acledabank.com.kh |
| អ៊ីម៉ែល | acledabank@acledabank.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៣០៧៧ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ០៦ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ចេញដោយ ធនាគារជាតិ នៃ កម្ពុជា |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ០៥៣/២០គ.ម.ក./ស.ស.រ. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ចេញដោយ គណៈកម្មការមូលបត្រកម្ពុជា បច្ចុប្បន្នជា និយ័តករមូលបត្រកម្ពុជា (“ន.ម.ក.”) |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | **បណ្ឌិត អ៊ិន ចាន់នី** |

### ខ- លក្ខណៈនៃធុរកិច្ច

ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាធនាគារពាណិជ្ជដែលមានសាខា និងបណ្តាញការិយាល័យធំជាងគេបង្អស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារបានចុះបញ្ជីនៅក្នុង ផ.ម.ក. ចាប់តាំងពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។ បច្ចុប្បន្ននេះធនាគារមានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន៤ រួមមាន៖ (១) ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត (២) ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា (៣) ក្រុមហ៊ុនអេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី និង (៤) វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ព្រមទាំងមានការិយាល័យតំណាងចំនួន១នៅប្រទេសមីយ៉ាន់ម៉ា។

### គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

- នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ធនាគារបានទទួលប័ណ្ណថ្លែងអំណរគុណពី **មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី “តេជោ”** សម្រាប់ការឧបត្ថម្ភកម្មវិធីនវានុវត្តន៍បញ្ជ្រាស ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី “តេជោ”។
- នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ធនាគារបានទទួលពានរង្វាន់ជាធនាគារឈានមុខគេប្រចាំឆ្នាំ២០២០ ពីក្រុមហ៊ុន VISA WORLDWIDE PTE. LIMITED។

- នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២១ គឺជាខួបលើកទី១៥៨ នៃទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ក្រោមប្រធានបទ "ទាំងអស់គ្នារួមជាមួយកាកបាទក្រហមកម្ពុជា ប្រយុទ្ធនឹងកូវីដ-១៩ និងកសាងភាពធន់របស់សង្គមជាតិ" ធនាគារបានទទួលប័ណ្ណថ្លែងអំណរគុណពីកាកបាទក្រហមកម្ពុជា សម្រាប់ការបរិច្ចាគថវិកាចំនួន ៨០០.០០០.០០០ រៀល។
- នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ ធនាគារបានទទួលប័ណ្ណថ្លែងអំណរគុណពីមូលនិធិគន្ធបុប្ផាកម្ពុជា សម្រាប់ការបរិច្ចាគថវិកាចំនួន ១.២០០.០០០.០០០ រៀល។
- នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ ធនាគារបានទទួលលិខិតថ្លែងអំណរគុណ និងកោតសរសើរពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថាជា ធនាគារ ដែលបានចូលរួមចំណែកបំពេញកាតព្វកិច្ចបង់ពន្ធដារផ្ទៃក្នុងជូនរដ្ឋច្រើនជាងគេ **លំដាប់ទី៤** ក្នុងចំណោមអ្នកបង់ពន្ធទាំងអស់ក្នុងឆ្នាំ២០២០។

## ផ្នែកទី ២-ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក-លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

- **ប្រតិបត្តិការក្នុងវិស័យធនាគារ**

  ត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២១ ធនាគារពាណិជ្ជមានចំនួន៥៤ (ធនាគារក្នុងស្រុកចំនួន២៤ បុត្រសម្ព័ន្ធធនាគារបរទេសចំនួន១៨ និងសាខាធនាគារបរទេសចំនួន១២) ធនាគារឯកទេសចំនួន១២ (ធនាគារក្នុងស្រុកចំនួន០៦ និងធនាគារបរទេសចំនួន០៦) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៨៣ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន០៦ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន៧៧) ក្រុមហ៊ុនភតិសន្យាចំនួន១៥ ការិយាល័យតំណាងធនាគារបរទេសចំនួន០៦ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ២៤ និងគ្រឹះស្ថានឥណទានជនបទចំនួន២៤៥ ។ (Source: NBC Report, CMA Report, and Actually Updated)

- **ប្រតិបត្តិការអាជីវកម្ម និងចំណែកទីផ្សាររបស់ធនាគារ អេស៊ីលីដា នៅក្នុងវិស័យធនាគារ:**

  ធនាគារ អេស៊ីលីដា ភីអិលស៊ី មានចំណែកទីផ្សារ ១៥,៥១% និង ១៣,៨៥% សម្រាប់ប្រាក់បញ្ញើ និងកម្ចីឥណទាន រៀងគ្នាគិតត្រឹមដំណាច់ខែមេសា ឆ្នាំ២០២១។

  គិតនៅត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២១ ធនាគារ អេស៊ីលីដា និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនទទួលបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី២ ឆ្នាំ២០២១ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
| **សេវាឥណទាន** | | | |
| ចំនួនឥណទានសកម្ម | ៥៤៥.៦៦៦ | ៥៥៥.៣២៣ | ៥៣៦.៨៩១ |
| សមតុល្យឥណទានសរុប (លានរៀល) | ១៩.៦១១.៨១២ | ១៨.២២៩.៣៧២ | ១៥.៨០៨.៨១៤ |
| **សេវាបញ្ញើ-សន្សំ** | | | |
| ចំនួនគណនីសរុប | ៣.០៤៧.៣០៧ | ២.៨៩៤.៩០៧ | ២.៦២០.៧៧៨ |
| ចំនួនទឹកប្រាក់សរុប (លានរៀល) | ២១.២៩៦.៩០២ | ១៨.៦៥២.៦៩០ | ១៧.៧៩៩.១៨៤ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី២ ឆ្នាំ២០២១ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
| **សេវាធនាគារអេឡិចត្រូនិក** | | | |
| **ប័ណ្ណអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនប័ណ្ណបោះផ្សាយសរុប | ១.៤៦៤.៦១៦ | ១.៣៩៦.៧៧៨ | ១.២៧៧.៧២៥ |
| ចំនួនប្រតិបត្តិការសរុប | ៩.៤៩៦.៧៤៧ | ១៩.៧៦៨.២២៣ | ២០.៤០៣.២០០ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៨.០៤៣.១៤៩ | ១៣.៧៧៥.៩១៨ | ១២.៥៤៨.០៦៦ |
| **អេស៊ីលីដាម៉ូបាល** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ២.០២៩.៣០៥ | ១.៧៨២.៨១៤ | ១.២៧៦.៥២៨ |
| ចំនួនប្រតិបត្តិការសរុប | ៣២.៧៣៤.៩៤០ | ៤៨.៧៤៩.៥៩៩ | ២៨.២៦៤.៩៧២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៤៨.៨០៥.១៩៩ | ៥៩.២១១.២៧៩ | ៣៧.៣០៣.១៣៧ |
| **អេស៊ីលីដាអ៊ីនធើណែត** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ១២.៥១៦ | ១១.៦៧៩ | ១១.៣៣១ |
| ចំនួនប្រតិបត្តិការសរុប | ៥៦៥.១៧៤ | ៨៨៦.៩៩០ | ៥១០.២៩៧ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៧.៤៨៩.២៤៨ | ១១.២៨៥.៩៤៨ | ៥.២៣៥.៦១៦ |
| **អេស៊ីលីដាអ៊ីខុមមើស** | | | |
| ចំនួនដៃគូអាជីវកម្មសរុប | ៥៣ | ៥១ | ៤៨ |
| ចំនួនប្រតិបត្តិការសរុប | ១.២៩៧.០៩០ | ៤៤៧.៩២៩ | ៤៦៧.៦៦៨ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៥០៧.៩៨៣ | ៣៦០.០០០ | ២១៣.២៦២ |
| **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនសរុប | ៨៤៦ | ៧៩០ | ៦៨៣ |
| ចំនួនប្រតិបត្តិការសរុប | ១២.៨០៧.៥៣៧ | ២៦.៥៧៤.៦៧៨ | ២៤.១៨១.២៣១ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១២.៤៨៩.៥៣៨ | ២០.១៩៨.៧២៤ | ១៥.៩២៩.១៩៧ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី២ ឆ្នាំ២០២១ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
| **ម៉ាស៊ីនឆូតកាតអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនឆូតកាតសរុប | ៤.២៩៥ | ៤.២៨៧ | ៤.២៨៩ |
| ចំនួនប្រតិបត្តិការសរុប | ៧៣៧.៨០៥ | ២.៤៥៧.៦២៦ | ២.៤១២.៩៣៨ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៨៦.៦១៣ | ៦៥៧.៥០៦ | ៨៤៩.៣៩២ |
| **កូដ QR នៅតាមហាងទំនិញនានា** | | | |
| ចំនួនពាណិជ្ជករបំពាក់កូដ QR | ៩៦.៧២០ | ៦៣.៧១៤ | ៣០.៩៨៩ |
| ចំនួនប្រតិបត្តិការសរុប | ១.២៣២.០០២ | ១.៨៤២.៩១៣ | ៧៣៥.៣១២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៩៩.០២៥ | ១៨៦.៦៩១ | ៩០.៨៨៦ |
| **បណ្តាញប្រតិបត្តិការ និង បុគ្គលិក** | | | |
| **ធនាគារ អេស៊ីលីដា ភីអិលស៊ី** | | | |
| ចំនួនការិយាល័យសរុប | ២៦២ | ២៦៣ | ២៦២ |
| ចំនួនបុគ្គលិកសរុប | ១២.០៣៦ | ១២.០១៣ | ១១.៩៩៧ |
| **ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ក្នុង និង ក្រៅប្រទេស)** | | | |
| ចំនួនការិយាល័យសរុប | ៥៧ | ៥៦ | ៥៣ |
| ចំនួនបុគ្គលិកសរុប | ១.៦៥០ | ១.៦៩១ | ១.៦៥៨ |

## ខ-រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២១ | | ត្រីមាសទី២ ឆ្នាំ២០២០ | | ត្រីមាសទី២ ឆ្នាំ២០១៩ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៥៧០.១២៦ | ៩១,១៤% | ៥១២.១៧៦ | ៨៩,៦៦% | ៤៩៩.០០៥ | ៨៨,28% |
| ២ | ចំណូលកម្រៃ និងជើងសា | ៣៨.៤៣០ | ៦,១៤% | ៤១.៣៣៤ | ៧,២៤% | ៤៧.៨៥៦ | ៨,47% |
| ៣ | ចំណូលផ្សេងៗ | ១៦.៩៦១ | ២,៧១% | ១៧.៧៣១ | ៣,១០% | ១៨.៤១៤ | ៣,២៦% |
| | **ចំណូលសរុប** | **៦២៥.៥១៧** | **១០០%** | **៥៧១.២៤១** | **១០០%** | **៥៦៥.២៧៥** | **១០០%** |

# ផ្នែកទី ៣-របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនកររងករាជ្យ

សូមពិនិត្យមើលឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ
របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយសវនកររងករាជ្យ

## ផ្នែកទី ៤-ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះផ្តោតសំខាន់លើលទ្ធផលប្រតិបត្តិការ និងលទ្ធផលហិរញ្ញវត្ថុដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេលគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុចន្លោះពេលត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា(ស.រ.ហ.អ.ក)។ មានតែសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់ធនាគារប៉ុណ្ណោះត្រូវបានយកមកធ្វើការពិភាក្សា និងវិភាគ។

## ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១-ការវិភាគចំណូល

ធនាគារ អេស៊ីលីដា ភីអិលស៊ី មានប្រភពចំណូលធំៗចំនួនបីគឺ ចំណូលការប្រាក់ ចំណូលកម្រៃនិងជើងសា និងចំណូលផ្សេងៗ។

- ចំណូលការប្រាក់៖ រួមមានចំណូលការប្រាក់ពីឥណទាននិងបុរេប្រទាន ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងការវិនិយោគហិរញ្ញវត្ថុ។
- ចំណូលកម្រៃ និងជើងសា៖ រួមមានកម្រៃជើងសា កម្រៃជើងសាបានពីភ្នាក់ងារធានារ៉ាប់រង កម្រៃពីម៉ាស៊ីនអេធីអឹម កម្រៃពីការសងឥណទានមុនកាលកំណត់ កម្រៃពីសេវាប្រាក់បញ្ញើ កម្រៃពីសេវាធានា និងកម្រៃពីការបណ្តុះបណ្តាល។
- ចំណូលផ្សេងៗ៖ រួមមានចំណេញពីការប្តូររូបិយប័ណ្ណ ចំណេញពីការលក់ទ្រព្យនិងបរិក្ខារ ភាគលាភលើការវិនិយោគហិរញ្ញវត្ថុ និងចំណូលផ្សេងៗ។

### ២-ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២១ | | ត្រីមាសទី២ ឆ្នាំ២០២០ | | ត្រីមាសទី២ ឆ្នាំ២០១៩ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៥៧០.១២៦ | ៩១,១៤% | ៥១២.១៧៦ | ៨៩,៦៦% | ៤៩៩.០០៥ | ៨៨,២៨% |
| ២ | ចំណូលកម្រៃ និងជើងសា | ៣៨.៤៣០ | ៦,១៤% | ៤១.៣៣៤ | ៧,២៤% | ៤៧.៨៥៦ | ៨,៤៧% |
| ៣ | ចំណូលផ្សេងៗ | ១៦.៩៦១ | ២,៧១% | ១៧.៧៣១ | ៣,១០% | ១៨.៤១៤ | ៣,២៦% |
| | **ចំណូលសរុប** | **៦២៥.៥១៧** | **១០០%** | **៥៧១.២៤១** | **១០០%** | **៥៦៥.២៧៥** | **១០០%** |

ចំណូលសរុបចំនួន ៦២៥,៥២ ប៊ីលានរៀល ក្នុងត្រីមាសទី២ ឆ្នាំ២០២១ ភាគច្រើនបានមកពីចំណូលការប្រាក់ដែលមានចំណែក ៩១,១៤% នៃចំណូលសរុប និងចំណូលសរុបបានកើនឡើងចំនួន ៥៤,២៨ ប៊ីលានរៀល ឬ ៩,៥០% បើប្រៀបធៀបទៅនឹងចំណូលសរុបក្នុងត្រីមាសទី២ ឆ្នាំ២០២០។

### ៣-ការវិភាគគម្លាតចំណេញដុល

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី បានរៀបចំក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីគម្លាតចំណេញដុលទេ។ ចំណូលការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុបដកនឹងចំណាយការប្រាក់សរុប នឹងត្រូវយកមកបង្ហាញនៅក្នុងការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ ដូចខាងក្រោម។

## ៤-ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២១ | ត្រីមាសទី២ ឆ្នាំ២០២០ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ចំណូលការប្រាក់ | ៥៧០.១២៦ | ៥១២.១៧៦ | ៥៧.៩៥០ | ១១,៣១% |
| ចំណាយការប្រាក់ | (១៧១.៧១៧) | (១៥៤.៨៣៧) | (១៦.៨៨០) | ១០,៩០% |
| **ចំណូលការប្រាក់សុទ្ធ** | **៣៩៨.៤០៩** | **៣៥៧.៣៣៩** | **៤១.០៧០** | **១១,៤៩%** |
| ចំណូលកម្រៃ និងជើងសា | ៣៨.៤៣០ | ៤១.៣៣៤ | (២.៩០៤) | -៧,០៣% |
| ចំណាយកម្រៃ និងជើងសា | (១.៨៧៩) | ៣៨៦ | (២.២៦៥) | ៥៨៦,៧៩% |
| **ចំណូលកម្រៃ និងជើងសាសុទ្ធ** | **៣៦.៥៥២** | **៤១.៧២០** | **(៥.១៦៨)** | **-១២,៣៩%** |
| ការខាតបង់ឱនភាពនៃតម្លៃរបស់ឥណទាននិងបុរេប្រទានប្រាក់បញ្ញើនៅធនាគារផ្សេង និងគណនីត្រូវទទួលផ្សេងៗ | (២៦.១១៣) | (៣៨.៤៦៣) | ១២.៣៥០ | -៣២,១១% |
| ការខាតបង់ឱនភាពនៃតម្លៃកិច្ចសន្យាក្រៅតារាងតុល្យការ | ៤ | ៨១៤ | (៨១០) | ៩៩,៥១% |
| **ការខាតបង់ឱនភាពនៃតម្លៃសុទ្ធ** | **(២៦.១០៩)** | **(៣៧.៦៤៨)** | **១១.៥៣៩** | **-៣០,៦៥%** |
| **ចំណូលបន្ទាប់ពីការខាតបង់ឱនភាពនៃតម្លៃ** | **៤០៨.៨៥២** | **៣៦១.៤១១** | **៤៧.៤៤១** | **១៣,១៣%** |
| ចំណូលផ្សេងៗ | ១៦.៩៦១ | ១៧.៧៣១ | (៧៧០) | -៤,៣៤% |
| ចំណាយទូទៅ និងរដ្ឋបាល | (២៣៨.២២៦) | (២១៩.៩៤០) | (១៨.២៨៦) | ៨,៣១% |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **១៨៧.៥៨៧** | **១៥៩.២០៣** | **២៨.៣៨៤** | **១៧,៨៣%** |

ប្រាក់ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញនៅត្រីមាសទី២ ឆ្នាំ២០២១ បានកើនឡើងចំនួន ២៨,៣៨ ប៊ីលានរៀល ឬ ១៧,៨៣% បើប្រៀបធៀបទៅនឹងត្រីមាសទី២ ឆ្នាំ២០២០ ដោយសារការកើនឡើងនៃចំណូលការប្រាក់សុទ្ធចំនួន ៤១,០៧ ប៊ីលានរៀល ឬ ១១,៤៩% និងការថយចុះការខាតបង់ឱនភាពនៃតម្លៃសុទ្ធចំនួន ១១,៥៤ ប៊ីលានរៀល ឬ ៣០,៦៥% កាត់បន្ថយដោយការថយចុះនៃចំណូលកម្រៃនិងជើងសាសុទ្ធចំនួន ៥,១៧ ប៊ីលានរៀល ឬ ១២,៣៩% និងការកើនឡើងនៃចំណាយទូទៅនិងរដ្ឋបាលចំនួន ១៨,២៩ ប៊ីលានរៀល ឬ ៨,៣១%។

## ៥-ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២១ | ត្រីមាសទី២ ឆ្នាំ២០២០ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **១៨៧.៥៨៧** | **១៥៩.២០៣** | **២៨.៣៨៤** | **១៧,៨៣%** |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៣៦.៧៩១) | (៣៥.៣៨៩) | (១.៤០២) | ៣,៩៦% |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **១៥០.៧៩៦** | **១២៣.៨១៤** | **២៦.៩៨២** | **២១,៧៩%** |

ប្រាក់ចំណេញក្នុងត្រីមាសទី២ ឆ្នាំ២០២១នេះ ខ្ពស់ជាងត្រីមាសទី២ ឆ្នាំ២០២០ ចំនួន ២៦,៩៨ ប៊ីលានរៀល ឬ ២១,៧៩%។ ការកើនឡើងនេះ ភាគច្រើនបណ្តាលមកពីការកើនឡើងនូវចំណូលការប្រាក់សុទ្ធចំនួន ៤១,០៧ ប៊ីលានរៀល ស្មើនឹង ១១,៤៩% ធៀបនឹងត្រីមាសទី២ ឆ្នាំ២០២០។

## ៦-ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| លទ្ធផលលម្អិតសរុប (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២១ | ត្រីមាសទី២ ឆ្នាំ២០២០ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **១៥០.៧៩៦** | **១២៣.៨១៤** | **២៦.៩៨២** | **២១,៧៩%** |
| **លទ្ធផលលម្អិតផ្សេងៗ៖** **ធាតុដែលនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញទៅចំណេញ ឬខាត៖** | | | | |
| ការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | (៨៤៨) | (៤.៨៥៥) | ៤.០០៧ | ៨២,៥៣% |
| **ធាតុដែលត្រូវ ឬអាចត្រូវបានចាត់ថ្នាក់ឡើងវិញនៅគ្រាបន្ទាប់ទៅចំណេញ ឬខាត៖** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | ៥.៩៦៩ | ៣.១៧៣ | ២.៧៩៦ | ៨៨,១២% |
| **លទ្ធផលចំណេញ/(ខាត)លម្អិតផ្សេងៗក្នុងរិយបរិច្ឆេទ** | **៥,១២១** | **(១,៦៨២)** | **៦,៨០៣** | **៤០៤.៤៦%** |
| **លទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | **១៥៥.៩១៧** | **១២២.១៣២** | **៣៣.៧៨៥** | **២៧,៦៦%** |

## ៧-ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ បាននិងកំពុងជះឥទ្ធិពលអវិជ្ជមានដល់អាជីវកម្មគ្រប់វិស័យទាំងអស់នៅជុំវិញពិភពលោករួមទាំងព្រះរាជាណាចក្រកម្ពុជាផងដែរ។ ស្របពេលជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជាបានដោះស្រាយស្ថានការណ៍ដ៏លំបាកនេះបានយ៉ាងល្អប្រសើរគួរជាទីមោទកភាព។ ជាលទ្ធផលឧស្សាហកម្មធំៗត្រូវបានការពារយ៉ាងល្អពីផលប៉ះពាល់នៃជំងឺរាតត្បាតដ៏គួរឲ្យភ័យខ្លាចមួយនេះ។ ទោះជាយ៉ាងណាក៏ដោយក៏មានសញ្ញាជាច្រើនបានបង្ហាញថាសកម្មភាពសេដ្ឋកិច្ចនឹងចាប់ផ្តើមរីកចម្រើនឡើងវិញនៅក្នុងឆ្នាំ២០២១ ដោយសារប្រសិទ្ធភាពនៃវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដែលបានដាក់ឲ្យប្រើប្រាស់នៅទូទាំងពិភពលោក។

ទោះបីជាមានការរីករាលដាលនៃជំងឺកូវីដ-១៩ ឆ្លងចូលក្នុងសហគមន៍ក្នុងព្រះរាជាណាចក្រកម្ពុជា នៅអំឡុងត្រីមាសទី២នៃឆ្នាំ២០២១ក្តី ក៏ធនាគារនៅតែបន្តពង្រីកសេវាស្វ័យប្រតិបត្តិការរបស់ខ្លួន ដើម្បីលើកកម្ពស់សមត្ថភាពក្នុងការឆ្លើយតបនឹងការវិវឌ្ឍបច្ចេកវិទ្យាចុងក្រោយបំផុត ឲ្យកាន់តែមានភាពងាយស្រួល រហ័សទាន់ចិត្ត សុវត្ថិភាពខ្ពស់ និងទទួលបានការគាំទ្រពីសាធារណជនគ្រប់មជ្ឈដ្ឋាន។ រូបរាងថ្មីនៃ **អេស៊ីលីដាម៉ូបាល** ជួយឲ្យអតិថិជនអាចធ្វើប្រតិបត្តិការធនាគារតាមអនឡាញបានកាន់តែងាយស្រួល នៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។ ការចូលរួមរបស់អតិថិជនរបស់យើងក្នុងការប្រើប្រាស់សេវាស្វ័យប្រតិបត្តិការធនាគារ គឺមិនត្រឹមតែបានបង្ហាញអំពីការផ្លាស់ប្តូរឥរិយាបថរបស់ពួកគាត់ក្នុងការប្រើប្រាស់សេវាកម្មតាមបែបប្រពៃណីប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងបានបង្ហាញអំពីការចូលរួមក្នុងការការពារការរីករាលដាលនៃជំងឺកូវីដ-១៩ ជាមួយនឹងរាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលផងដែរ។

## ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១-ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ធនាគារ អេស៊ីលីដា ទទួលបានជោគជ័យនៅលើទីផ្សារដែលនាំមកនូវផលចំណេញអាស្រ័យដោយកត្តាពីរគឺ៖

- កំណើនសំពៀតឥណទាន ដោយសារតម្រូវការខ្ពស់នៅលើទីផ្សារលើផលិតផលឥណទានរបស់ធនាគារ ជាពិសេសវិស័យ SME។
- កំណើនប្រាក់បញ្ញើ-សន្សំ របស់ធនាគារ រួមជាមួយផលិតផល និងសេវាកម្មផ្សេងទៀត។

កត្តាទាំងពីរនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងការអភិវឌ្ឍឥតឈប់ឈរនៃប្រព័ន្ធឌីជីថលរបស់ធនាគារ ដែលផ្តល់ជូនអតិថិជននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងទាន់សម័យ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី កំពុងតែអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធឲ្យកាន់តែទូលំទូលាយសម្រាប់ជាជម្រើសដ៏សម្បូរបែបជាមួយនឹងការិយាល័យទាំង៣១៩ តាមរយៈការផ្លាស់ប្តូរបន្តិចម្តងៗទៅជាមជ្ឈមណ្ឌលដែលអាចធ្វើស្វ័យប្រតិបត្តិការ ព្រមទាំងមាន**ម៉ាស៊ីនអេធីអឹមអេស៊ីលីដា**ចំនួន៨៤៦គ្រឿង និងម៉ាស៊ីនឆូតកាតចំនួន៤.២៩៥គ្រឿង។ ចំណុចគួរជាទីមោទកភាពគឺធនាគារ អេស៊ីលីដា បានបោះពុម្ពប័ណ្ណ**អេធីអឹមអេស៊ីលីដា**ចំនួន១,៤៦លានប័ណ្ណជូនដល់អតិថិជន។ បន្ថែមលើនេះ **អេស៊ីលីដាម៉ូបាល** បានទទួលប្រជាប្រិយភាពយ៉ាងខ្លាំងដែលមានអ្នកចុះឈ្មោះប្រើប្រាស់ច្រើនជាង២,០៣លាននាក់ នៅដំណាច់ខែមិថុនា ឆ្នាំ២០២១នេះ។

ការបង្កើនភាពងាយស្រួលដល់អតិថិជន និងពង្រឹងប្រព័ន្ធសុវត្ថិភាពអ៊ិនធើណែត គឺជាចំណុចដែលធនាគារ អេស៊ីលីដា ផ្តោតការយកចិត្តទុកដាក់បំផុត។ ដើម្បីសម្រេចនូវវឌ្ឍនភាពគោលដៅដ៏រឹងមាំទាំងនេះ ធនាគារនឹងបន្តលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមរយៈការវិនិយោគលើបច្ចេកវិទ្យាទំនើបចុងក្រោយ ពង្រឹងសមត្ថភាពធនធានមនុស្ស ព្រមទាំងពង្រីកនិងកែលម្អដំណើរការអាជីវកម្ម។ ជាយុទ្ធសាស្រ្ត ធនាគារកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដែលអាចឱ្យដៃគូទាំងក្នុង និងក្រៅប្រទេសអាចភ្ជាប់ប្រព័ន្ធនេះដើម្បីបម្រើអតិថិជនទៅវិញទៅមក និងឆ្លងព្រំដែន។ ប្រព័ន្ធនេះមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់អតិថិជនដ៏ឆ្លាតវៃរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដៃគូអាជីវកម្មរបស់ពួកគាត់ផងដែរ។ យើងខ្ញុំទទួលស្គាល់ថាអតិថិជន និងដៃគូអាជីវកម្មទាំងអស់គឺជាបណ្តាញតភ្ជាប់ដ៏មានសារសំខាន់សម្រាប់ពង្រីកសេវាកម្មរបស់ធនាគារ និងរីកចម្រើនជាមួយគ្នា។

**អេស៊ីលីដាម៉ូបាល** បានកែលម្អយ៉ាងទូលំទូលាយ និងផ្លាស់ប្តូររូបរាងថ្មី កាន់តែទំនើប ងាយស្រួល និងមានសុវត្ថិភាពខ្ពស់ ជាមួយនឹងមុខងារពិសេសៗជាច្រើន ។ ឥឡូវនេះ អតិថិជនទាំងអស់អាចប្រតិបត្តិការប្រាក់បញ្ញើ-សន្សំ (សំចៃ ចរន្ត និងមានកាលកំណត់) តាមរយៈ **អេស៊ីលីដាម៉ូបាល** បានភ្លាមៗ ថែមទាំងទទួលបានការប្រាក់ខ្ពស់ទៀតផង។ លោកអ្នកក៏អាចដាក់ប្រាក់បញ្ញើមានកាលកំណត់ដោយខ្លួនឯងបានយ៉ាងងាយស្រួល ជាមួយម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់ផងដែរ។

ធនាគារក៏បាន និងកំពុងបន្តវិនិយោគក្នុងការពង្រីកទីតាំងស្វ័យសេវាធនាគារ ដោយធ្វើការដំឡើងបន្ថែមនូវ **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** ម៉ាស៊ីនដក-ដាក់ប្រាក់ ម៉ាស៊ីនឆូតកាត និងការពង្រីកបណ្តាញទូទាត់តាម QR របស់ខ្លួន។

ដើម្បីគាំទ្រដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (ក្នុងអំឡុងពេលនៃការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩) ឱ្យមានសន្ទនីយភាពបន្ថែមទៀតដើម្បីឆ្លើយតបទៅនឹងតម្រូវការទុនរបស់ខ្លួន ធនាគារជាតិនៃកម្ពុជា បានបន្ធូរបន្ថយអនុបាតមួយចំនួនដូចជា៖ សាធនភាពទ្រនាប់ដើមទុន ប្រាក់បម្រុងកាតព្វកិច្ច។ល។ ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកាត់បន្ថយពន្ធកាត់ទុកលើការប្រាក់កម្ចី ក៏ដូចជាបង្កើតសន្ទនីយភាពបន្ថែមទៀតនៅលើទីផ្សារដែលមានថ្លៃដើមទាប។ កត្តាទាំងនេះបានផ្តល់ឱកាសសម្រាប់ការប្រកួតប្រជែងថ្លៃដែលអាចប៉ះពាល់ដល់ចំណូលរបស់ធនាគារក្នុងរយៈពេលខ្លី ប៉ុន្តែវានឹងជួយឱ្យមានភាពរឹងមាំសម្រាប់រយៈពេលវែង។

### ២-ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ធនាគារ អេស៊ីលីដា ភីអិលស៊ី ប្រតិបត្តិការក្នុងវិស័យសេវាកម្ម ដែលការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនអាចអនុវត្តបានចំពោះធនាគារឡើយ។

### ៣-ការវិភាគលើពន្ធ

ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃប្រទេសនីមួយៗ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធមានកាតព្វកិច្ចបង់ពន្ធតាមការកំណត់របស់អាជ្ញាធរពន្ធដារនីមួយៗ។

ការបង់ពន្ធជូនអគ្គនាយកដ្ឋានពន្ធដារមិនត្រឹមតែជាកាតព្វកិច្ច និងការទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ **"មាស"** ពីអគ្គនាយកដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ ២០២០ ដល់ ២០២១ ប៉ុណ្ណោះទេ ប៉ុន្តែជាការចូលរួមចំណែកក្នុងសង្គម និងកំណើនសេដ្ឋកិច្ចផងដែរ។

ចំណូលពន្ធគឺជាប្រភពចំណូលដ៏សំខាន់បំផុតសម្រាប់ប្រទេស។ រដ្ឋាភិបាលប្រមូលពន្ធកាន់តែច្រើន ការចូលរួមវិភាគទានកាន់តែច្រើនដល់ការអភិវឌ្ឍប្រទេស។ ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាធនាគារដែលបានបង់ពន្ធដារច្រើនបំផុតលំដាប់ទី៤ ក្នុងចំណោមអ្នកបង់ពន្ធទាំងអស់ក្នុងឆ្នាំ២០២០។ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានមោទកភាពដែលអាចចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយើង។

### ៤-ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

ធនាគារមិនមានធាតុ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលខុសពីធម្មតាជាសារវន្តនោះទេ។ ទោះជាយ៉ាងណាក៏ដោយ លក្ខខណ្ឌសេដ្ឋកិច្ចដែលបានរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសវីរុសកូវីដ-១៩បំប្លែងថ្មី ឆ្លងចូលក្នុងសហគមន៍ក្នុងព្រះរាជាណាចក្រកម្ពុជានៅត្រីមាសទី២ ឆ្នាំ២០២១នេះ អាចជះឥទ្ធិពលដល់សមត្ថភាពសងត្រលប់មកវិញរបស់អតិថិជន ដែលគុណភាពឥណទានរបស់ធនាគារអាចរងផលប៉ះពាល់បន្តិចបន្តួច។

## គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ដើម្បីចូលរួមគាំទ្រការរីកលូតលាស់អាជីវកម្មរបស់អតិថិជន ធនាគារ អេស៊ីលីដា ភីអិលស៊ី បានបញ្ចុះអត្រាការប្រាក់លើការស្នើសុំឥណទានថ្មីគ្រប់ប្រភេទ និងដោយកាន់តែមានភាពងាយស្រួល អតិថិជនទាំងអស់អាចដាក់សំណើសុំឥណទានតាមរយៈ **អេស៊ីលីដា ម៉ូបាល**។ ជាលទ្ធផល សមតុល្យឥណទានដុលសរុបនៅត្រីមាសទី២ ឆ្នាំ២០២១ មានការកើនឡើងចំនួន ១,៣៨ ទ្រីលានរៀល ស្មើនឹង ៧,៥៨% ធៀបនឹងដំណាច់ឆ្នាំ២០២០។

## ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

សម្រាប់ត្រីមាសទី២ ឆ្នាំ២០២១ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបានបន្តមានស្ថិរភាពទោះបីក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ រាតត្បាតក៏ដោយ។ តម្លៃរបស់ប្រាក់រៀលស្ថិតនៅចន្លោះពី ៤.០៧១ ទៅ ៤.១០៨ ក្នុងមួយដុល្លារអាមេរិក តម្លៃនេះប្រហាក់ប្រហែលទៅនឹងតម្លៃប្រាក់រៀលនៃរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានអនុវត្តយ៉ាងម៉ឺងម៉ាត់តាមបទប្បញ្ញត្តិ និងគោលនយោបាយផ្ទៃក្នុងធនាគារ ទាក់ទងទៅនឹងស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណ។ អាស្រ័យហេតុនេះ ផលប៉ះពាល់ពីការប្រែប្រួលអត្រាប្តូរប្រាក់លើអាជីវកម្មធនាគារមានតិចតួចបំផុត។ ផលប៉ះពាល់នេះ ត្រូវបានវាស់វែង តាមដាន និងគ្រប់គ្រងជាប្រចាំថ្ងៃ ដើម្បីចាត់វិធានការដោះស្រាយបានទាន់ពេលវេលា តាមការចាំបាច់។

ទាក់ទងនឹងអត្រាការប្រាក់ ធនាគារបានដំណើរការអាជីវកម្មរបស់ខ្លួនដោយផ្អែកលើរបបអត្រាការប្រាក់ថេរ (ទាំងប្រាក់បញ្ញើនិងប្រាក់កម្ចី) ដែលមិនមានទំនាក់ទំនងផ្ទាល់ជាមួយចលនាអត្រាការប្រាក់នៅក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិឡើយ។ ចំពោះទីផ្សារក្នុងស្រុកវិញ មានការប្រែប្រួលអត្រាការប្រាក់តិចតួចដោយសារការប្រកួតប្រជែងតម្លៃទីផ្សារ។ ដូច្នេះផលប៉ះពាល់នៃការប្រែប្រួលអត្រា

ការប្រាក់លើអាជីវកម្មរបស់ធនាគារគឺតិចតួចបំផុត ហើយការប្រែប្រួលនោះស្ថិតក្នុងការរំពឹងទុកនិងការត្រួតពិនិត្យ។ លើសពីនេះ ហានិភ័យអត្រាការប្រាក់ត្រូវបានវាស់វែង តាមដាន និងចាត់ចែងជាប្រចាំខែដើម្បីចាត់វិធានការដោះស្រាយទាន់ពេលវេលា ចៀសវាងបាននូវផលប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធផលនៃអាជីវកម្មរបស់ធនាគារ។

ធនាគារមិនបានធ្វើប្រតិបត្តិការជួញដូរនានាដែលមានទម្រង់ជាទំនិញ (Commodity) នោះទេ។

## ង-ផលប៉ះពាល់នៃអតិផរណា

អត្រាអតិផរណាសម្រាប់ឆ្នាំ២០២១ ត្រូវបានព្យាករថាមានកម្រិត ៣,១% ដែលជាកម្រិតទាបមធ្យម។ ចំពោះប្រតិបត្តិការរបស់ធនាគារគឺមិនមានពាក់ព័ន្ធច្រើនជាមួយកម្រិតអតិផរណាឡើយ ដូច្នេះផលប៉ះពាល់នៃអតិផរណាមកលើអាជីវកម្មរបស់ធនាគារគឺមានតិចតួចបំផុត។

## ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល

- **គោលនយោបាយសេដ្ឋកិច្ច៖**

សម្រាប់ដំណាច់ឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជាបានប៉ាន់ស្មានសេដ្ឋកិច្ចកម្ពុជាជាថ្មីថានឹងទទួលកំណើនវិជ្ជមាន ៤% ទាបជាងការរំពឹងទុកកាលពីចុងឆ្នាំ២០២០ ដោយឈរលើមូលដ្ឋាន (១) វិស័យកម្មន្តសាលកម្ពុជារំពឹងមានកំណើនវិជ្ជមានមកវិញ ឈរលើបរិការណ៍នៃការងើបឡើងនៃសេដ្ឋកិច្ចពិភពលោក ជាពិសេសប្រទេសអភិវឌ្ឍន៍ជាដៃគូពាណិជ្ជកម្ម។ (២) លំហូរវិនិយោគផ្ទាល់ពីបរទេសរំពឹងថានឹងកើនឡើង ដែលអាចជួយធ្វើពិពិធកម្មផលិតកម្ម និងគាំទ្រដល់វិស័យសំណង់ និងអចលនទ្រព្យ។ (៣) ចំពោះវិស័យទេសចរណ៍ ការតម្រូវឲ្យមានការធ្វើចត្តាឡីស័ក ការព្រួយបារម្ភការឆ្លងជំងឺកូវីដ-១៩ និងការធ្លាក់ចុះនៃប្រាក់ចំណូល នឹងបន្តដាក់សម្ពាធលើវិស័យនេះក្នុងរយៈពេលខ្លី និងមធ្យមបន្ថែមទៀត។ (៤) វិស័យកសិកម្មរំពឹងបន្តរក្សាបានកំណើនល្អប្រសើរ ដោយសារសក្តានុពលនៃការបង្កបង្កើនផល និងការទាក់ទាញការវិនិយោគ និងវិធានការគាំទ្ររបស់រាជរដ្ឋាភិបាល។ ចំណែកឯស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានាដូចជា មូលនិធិហិរញ្ញវត្ថុអន្តរជាតិ ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី បានព្យាករថា កំណើនសេដ្ឋកិច្ចកម្ពុជាអាចសម្រេចបានក្នុងអត្រាពី ៤,០% ទៅ ៤,២% សម្រាប់ឆ្នាំ២០២១ និងពី ៥,២% ទៅ ៦,០% សម្រាប់ឆ្នាំ២០២២។

នៅឆមាសទី១ ឆ្នាំ២០២១នេះ ស្ថានភាពសេដ្ឋកិច្ចកម្ពុជា នៅតែបន្តទទួលរងផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងនោះវិស័យទេសចរណ៍ ភ្ញៀវទេសចរក្នុងស្រុកបន្តធ្លាក់ចុះ -៣៨% (មកត្រឹម ១,៦លាននាក់) រីឯភ្ញៀវទេសចរអន្តរជាតិចូលមកកម្ពុជាបន្តធ្លាក់ចុះខ្លាំង -៩០,៨% (មកត្រឹម ១០៨ពាន់នាក់) ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ស្របគ្នានេះ តម្លៃផលិតផលសរុបក្នុងវិស័យកម្មន្តសាលថយចុះប្រមាណ -២៤% ក្នុងនោះតម្លៃផលិតផលសម្រាប់ឧស្សាហកម្មនាំចេញថយចុះប្រមាណ -១៥% និងតម្លៃផលិតផលសម្រាប់បម្រើទីផ្សារក្នុងស្រុកថយចុះ-៤០%។ រីឯគម្រោងសំណង់ថ្មីៗក្នុងវិស័យសំណង់បានថយចុះគួរឲ្យកត់សម្គាល់ដោយចំនួនគម្រោង តម្លៃ និងផ្ទៃក្រឡាសំណង់បានធ្លាក់ចុះ -១១,៤% ; -៣៤,៣% និង -២៩,៩% រៀងគ្នា ខណៈដែលគម្រោងសំណង់ដែលមិនទាន់បញ្ចប់ការសាងសង់ នៅបន្តសកម្មភាពជាប្រក្រតី។ ផ្ទុយមកវិញ វិស័យកសិកម្មបន្តមានវឌ្ឍនភាពល្អ ដោយក្នុងនោះផលិតផលស្រូវនៅបន្តភាពល្អប្រសើរ ផលនេសាទនៅបន្តទទួលផលដូចឆ្នាំមុន (ខណៈដែលការចិញ្ចឹមត្រី និងបង្គាមានកំណើន ៦,៦%) រីឯផលកៅស៊ូសម្រេចមានកំណើនខ្ពស់ ៥,៨% ដោយតម្លៃកៅស៊ូបានកើនឡើងដល់ ១.៧៩២ ដុល្លារ ក្នុង ១តោន។ ទន្ទឹមនឹងនេះ សកម្មភាពនាំចេញផលិតផលមិនមែនកាត់ដេរ (ដូចជា កង់ គ្រឿងដង្គំ អេឡិចត្រូនិច ផលិតផលធ្វើពីឈើ និងផលិតផលកសិកម្មផ្សេងទៀត) បាននិងកំពុងរក្សាកំណើនល្អផងដែរ។ ចំពោះអតិផរណារួមជាមធ្យមមានកម្រិត ២,៥% ទាបជាងឆមាសទី២ ឆ្នាំ២០២០ (៣,១%) ក្នុងនោះ អតិផរណាក្រុមម្ហូបអាហារមានកម្រិត ២,៩% រីឯថ្លៃទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈបានបន្តប្រែប្រួលពី -៣,៣% ទៅ ៥,៣%។ រីឯអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកជាមធ្យមក្នុងឆមាសទី១នេះ មានចំនួន ៤.០៨៥ រៀលក្នុង១ដុល្លារអាមេរិក កើនឡើង ០,២% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។[(១),(២),(៣),(៤)]

- **គោលនយោបាយសារពើពន្ធ៖**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានគាំទ្រលើវិធានការដែលបានដាក់ចេញរបស់អគ្គនាយកដ្ឋានពន្ធដារ និងបានផ្ដល់អនុសាសន៍សំខាន់ៗ ជាទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០២១ រួមមាន៖ (១) ត្រូវយកចិត្តទុកដាក់ ពិនិត្យ និងសិក្សាលើលទ្ធភាពនៃការប្រមូលចំណូលដែលមានសក្ដានុពលផ្សេងទៀត ដោយគិតគូរទាំងទិដ្ឋភាពចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ដើម្បីធានាបាននូវអនុលោមភាពសារពើពន្ធ និងការប្រមូលចំណូលឱ្យបានគ្រប់ជ្រុងជ្រោយ ក្នុងនោះប្រភពចំណូលពីវិស័យ E-Commerce វិស័យប្រេងកាតដែលជាសក្ដានុពលថ្មី វិស័យធនធានរ៉ែ ព្រមទាំងវិស័យដែលមានសក្ដានុពលមួយចំនួនទៀត។ (២) រៀបចំកែសម្រួលបទប្បញ្ញត្តិក្នុងការកំណត់និយមន័យសហគ្រាសធុនតូច និងមធ្យម និងជំរុញសម្រួលលើកកម្ពស់សហគ្រាសធុនតូច និងមធ្យមចូលក្នុងប្រព័ន្ធ ក្នុងគោលដៅជំរុញកំណើន និងបង្កើតជាកាលានុវត្តភាពសេដ្ឋកិច្ច។ (៣) ពង្រឹងការចុះបញ្ជីពន្ធដារ និងជំរុញការបំពេញកាតព្វកិច្ចសារពើពន្ធសម្រាប់សហគ្រាសក្នុងវិស័យកាស៊ីណូ ដើម្បីធានាឱ្យបាននូវតម្លាភាពសារពើពន្ធ និងការគ្រប់គ្រងប្រមូលចំណូលពន្ធឱ្យបានជាអតិបរមា។ (៤) បន្តអនុវត្តកំណែទម្រង់ស្ថាប័ន ទំនើបកម្មរដ្ឋបាលសារពើពន្ធ-ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយធានាយ៉ាងណាបង្កភាពងាយស្រួល (User Friendly) សម្រាប់អ្នកជាប់ពន្ធ និងមន្ត្រី ព្រមទាំងពង្រឹងអនុលោមភាពសារពើពន្ធ ដើម្បីជំរុញប្រសិទ្ធភាព និងភាពប្រទាក់ក្រឡាក្នុងការបំពេញបេសកកម្មគ្រប់គ្រងប្រមូលចំណូលពន្ធ។ (៥) បន្តអនុវត្តប្រកបដោយការយកចិត្តទុកដាក់នូវយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល។ (៦) បន្តពង្រឹងការអនុវត្តឱ្យមានប្រសិទ្ធភាពនូវការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (IT Platform) ស្របតាមខ្លឹមសារអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០។ (៧) ពង្រឹង និងយកចិត្តទុកដាក់លើការធ្វើសវនកម្ម ស្របតាមខ្លឹមសារប្រកាសលេខ ២៧០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ ស្ដីពីសវនកម្មពន្ធដារ ដែលជាជញ្ជីងវាស់នូវអនុលោមភាពរបស់សហគ្រាស និងចៀសវាងការបង្កការលំបាកដល់អ្នកជាប់ពន្ធ។ (៨) បន្តលើកកម្ពស់ និងបញ្ជ្រាបវប្បធម៌មិនបង់ពន្ធ ពង្រឹងការផ្សព្វផ្សាយ និងអនុវត្តបទប្បញ្ញត្តិថ្មីពាក់ព័ន្ធនឹងពន្ធដារជូនដល់មន្ត្រីអនុវត្តផ្ទាល់ អ្នកជាប់ពន្ធ និងសាធារណជន ដើម្បីពន្យល់ និងដោះស្រាយការលំបាក និងចម្ងល់របស់ប្រជាពលរដ្ឋ។ (៩) បន្តកិច្ចសហការ និងពិគ្រោះយោបល់ជាមួយវិស័យពាក់ព័ន្ធ ដើម្បីទទួលយកធាតុចូលក្នុងការសិក្សារៀបចំ និងកែលម្អបទប្បញ្ញត្តិពាក់ព័ន្ធចាំបាច់នានា។ [៥]

សម្រាប់ឆមាសទី១ ឆ្នាំ២០២១នេះ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រមូលចំណូលបានចំនួន ៦.១៣៩,៤១ ប៊ីលានរៀល (ប្រមាណជា ១.៥១៥,៩០ លានដុល្លារអាមេរិក) ស្មើនឹង ៦៧,៥៨% នៃផែនការច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ធៀបនឹងចំណូលពន្ធ-អាករក្នុងរយៈពេលដូចគ្នាឆ្នាំ២០២០ ឃើញថាថយចុះចំនួន ៧២៧,៩៨ ប៊ីលានរៀល (ប្រមាណជា ១៧៩,៧៥ លានដុល្លារអាមេរិក) ស្មើនឹង -១០,៦០%។ [៦],[៧],[៨]

- **គោលនយោបាយរូបិយវត្ថុ៖**

ដើម្បីរួមចំណែកគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្ដារកំណើនសេដ្ឋកិច្ច ធនាគារជាតិ នៃ កម្ពុជា បានកំណត់គោលនយោបាយរូបិយវត្ថុចំនួន៤ សម្រាប់អនុវត្តនៅឆ្នាំ២០២១ រួមមាន៖ (១) ការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឲ្យស្ថិតក្នុងកម្រិតសមស្រប (២) រក្សាស្ថិរភាពអត្រាប្ដូរប្រាក់ ដើម្បីរួមចំណែកស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជន (៣) លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលតាមយន្តការទីផ្សារ និង (៤) ជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារតាមរយៈការបង្កើនឧបករណ៍គោលនយោបាយរូបិយវត្ថុចាំបាច់ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ។

សម្រាប់ឆមាសទី១នេះ រូបិយវត្ថុទូទៅ (M2) ត្រូវបានប៉ាន់ថាកើនឡើង ១៩% ខ្ពស់ជាងកំណើនក្នុងគ្រាដូចគ្នាក្នុងឆ្នាំមុន (១២,៣%) ដែលគាំទ្រជាចម្បងដោយកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណចំនួន ១៧,២% កើនឡើង ៩,២% កំណើនរូបិយវត្ថុក្នុងចរាចរណ៍ចំនួន ២៧,១% កើនឡើង ២៨% និងកំណើនប្រាក់បញ្ញើជាប្រាក់រៀលចំនួន ៣១% កើនឡើង ៣៨,២% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ព្រមទាំងការបញ្ចេញសន្ទនីយភាពទៅក្នុងសេដ្ឋកិច្ច តាមរយៈការធ្វើប្រតិបត្តិការ LPCO ចំនួន ១២ លើក ដោយបានផ្ដល់សន្ទនីយភាពជាប្រាក់រៀលចំនួន ៣,២ ទ្រីលានរៀល (៧៨៨ លានដុល្លារអាមេរិក) កើនឡើង ១២,៩%។ ឆ្លើយតបនឹងតម្រូវការ និងដើម្បីគ្រប់គ្រងសម្ពាធលើអត្រាប្ដូរប្រាក់ ធនាគារជាតិ នៃ កម្ពុជា បានធ្វើអន្តរាគមន៍លក់ប្រាក់ដុល្លារអាមេរិកដល់ទីផ្សារប្រមាណ ៤៨,៥ លានដុល្លារអាមេរិក និងបានទិញប្រាក់ដុល្លារអាមេរិកពីរាជរដ្ឋាភិបាលចំនួន ២៦,៧ លានដុល្លារអាមេរិក ហើយបានស្រូបសន្ទនីយភាពពីប្រព័ន្ធធនាគារវិញ តាមរយៈការចេញផ្សាយមូលបត្រអាចជួញដូរបាន (NCD) សរុបចំនួន ៦៧,៣

ទ្រីលានរៀល (ស្មើនឹង ១៦,៦ ប៊ីលានដុល្លារអាមេរិក) កើនឡើង ១៧,៦% ក្នុងនោះ NCD ជាប្រាក់រៀលមានចំនួន ៧,៣ ទ្រីលានរៀល កើនឡើង ៣៣,៤% និង NCD ជាប្រាក់ដុល្លារអាមេរិកមានចំនួន ១៤,៨ ប៊ីលានដុល្លារអាមេរិក កើនឡើង ១៥,៩%។ [១]

ឯកសារយោង:


(១) https://www.nbc.org.kh/download_files/publication/annual_rep_kh/Semi_Annual_Report_2021_Final.pdf

(២) https://kohsantepheapdaily.com.kh/article/1312716.html

(៣) https://www.khmertimeskh.com/50836213/imf-forecasts-4-2-growth-for-cambodia-this-year-and-6-0-next-year/

(៤) https://www.worldbank.org/en/news/press-release/2021/06/16/cambodia-country-economic-update-june-2021-cambodia-s-economy-recovering-but-uncertainties-remain

(៥) https://dap-business.com/finance/2021/01/13/4567/

(៦) http://www.freshnewsasia.com/index.php/en/localnews/205959-2021-07-20-12-07-31.html

(៧) https://cambodianewsservice.com/over-us1-5-billion-collected-as-tax-revenue-in-first-semester/

(៨) https://www.khmertimeskh.com/50898476/over-1-5-billion-collected-in-tax-revenue-in-first-semester/


**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ**

ថ្ងៃអង្គារ ២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១

បានអាន និងឯកភាព

ហត្ថលេខា

**ឆាយ សឿន**

**ប្រធានក្រុមប្រឹក្សាភិបាល**

អេស៊ីលីដា
ACLEDA BANK